# អវកាស ទទេ




## អវកាស ទទេ

**Espace vide**

យុទ្ធសាស្ត្រ របស់វៀតណាម ពាក់ព័ន្ធនឹង ស្រុកខ្មែរ តាំងពី ឆ្នាំ ១៩៧៩ មក គឺ ទុក ស្រុកខ្មែរ ជា អវកាស ទទេ។ នៅក្នុង អវកាសនោះ គេប្រឌិឌ ទ្រឹស្តី ថា ស្រុកខ្មែរ ជា ស្រុកមាន ពហុជាតិសាស្ត្រ តាំងពីកំណើត មក ហើយ ជាតិសាសន៍ខ្មែរ គ្រាន់តែជា សមាសភាពមួយ ក្នុង ចំណោមជាតិសាសន៍ដទៃ។ ដូចនេះ គេបង្កើត អត្តសញ្ញាណថ្មី សំរាប់ប្រជាជន រស់នៅលើទឹកដីខ្មែរ គឺ ‹ប្រជាជន កម្ពុជា› ដែលជា ការប្រមូលរួម (collection) នៃ ជនជាតិផ្សេងៗ គឺមាន ខ្មែរ, យួន, ចិន, ចាម, ជនជាតិភ្នំ ។ល។

ទ្រឹស្តីនេះ គឺ ជា ការលុបបំបាត់ អត្តសញ្ញាណខ្មែរ ជា ប្រជាជាតិ មាន ឫសគល់ ពិតប្រាកដ ហើយ កសាង អរិយធម៌, ប្រវត្តិសាស្ត្រខ្លួន ដោយ អត្តពោលអះអាង[1] នូវ អត្តភាពពិត របស់ខ្លួន ចំពោះអ្នកដទៃ។ ដូចនេះ ប្រជាពលរដ្ឋ មិនមែនគ្រាន់តែ ការ ប្រមូលរួម នៃ បុគ្គល ឬ ជាតិសាសន៍ នោះឡើយ, វាជា ព្រលឹងជាតិ មាន គ្រឹះ ជា តម្លៃ ដែលមាននៅក្នុងខ្លួន[2] កើតចេញពី

---

1 អត្តពោលអះអាង ជា ពាក្យខ្ញុំយកមកប្រើដើម្បីសំរួលការសរសេរ ដែលមានន័យ ពាក្យបារាំងថា s'affirmer។

2 តម្លៃ ដែលមាននៅក្នុងខ្លួន ; valeur intrinsèque។

## អវកាស ទទេ

អភិក្រម នៃ ការបង្កើត[3] នៃ អរិយធម៌ និង វប្បធម៌ មួយ ដ៏យូរ អង្វែង

ទ្រឹស្តី របស់យួននេះ ត្រូវ របប ដឹកនាំនៅស្រុកខ្មែរសព្វថ្ងៃ គេ យកមកធ្វើជារបស់ខ្លួន ក្នុងនាម សន្តិភាព ហើយ ពួកអ្នក ដឹកនាំ គណបក្សប្រឆាំង ចូលរួម អនុវត្ត ទាំងស្រុង ក្នុងនាម ជា អ្នក មិនប្រកាន់ពូជសាសន៍ គឺថា ជា អ្នក ប្រកបដោយ គតិបណ្ឌិត (le sage)។ តាមការពិត ទ្រឹស្តី នោះ មាន បារមី នៅ ស្រុកខ្មែរ គឺដោយសារ ប្រជាពលរដ្ឋខ្មែរ សូម ចុះចាញ់ តែម្តង នៅចំពោះមុខ អំណាចយួន នៅស្រុកខ្មែរ ក្នុងនាម នៃ គំនិត កម្មផល រឺឯ គំនិតចិត្តល្អ របស់ ពួកអ្នកដឹកនាំ គណបក្ស ប្រឆាំង និង ចាគប័ត្រ[4] (résignation) នៃ ពួកអ្នកចេះដឹងខ្មែរ វិញ វាមាន សភាព ដូចគ្នានឹង ការសុំចុះចាញ់ នោះដែរ។ ដូច នេះ ប្រជាជាតិខ្មែរ សព្វថ្ងៃ មាន សភាព ជា ប្រជាជាតិ ឋិតនៅ ក្នុង អវកាស ទទេ ដែលនៅក្នុងនោះ គេអាចយក វត្ថុធាតុ អ្វី គ្រប់បែបយ៉ាង មកដាក់ ក៏បានដែរ។ ការចុះចាញ់នោះ រុញ អភិក្រម នៃ ការលុបបំបាត់ អត្តសញ្ញាណ សហស្សវត្ស របស់ ប្រជាជាតិខ្មែរ អោយ កាន់តែលឿនឡើង ហើយ បង្កើតជា អវកាស ទទេ នៅ ស្រុកខ្មែរថ្មី អោយកាន់តែ ធំឡើង សំរាប់ កសាង មហាវៀតណាម។ ម្លោះហើយ អត្តសញ្ញាណខ្មែរថ្មី គឺ ជា ជាតិសាសន៍ ភាគតិចមួយ នៅ ឥណ្ឌូចិន យួនូបនីយកម្ម គឺថា

[3] អភិក្រម នៃ ការបង្កើត ; processus de formation។
[4] ចាគប័ត្រ, ការបោះបង់សិទ្ធរបស់ខ្លួនអោយអ្នកដទៃ; résignation។

## អវកាស ទទេ

ជាតិសាសន៍ខ្មែរ វាគ្រាន់តែ ស្ថិត នៅក្នុង ការបង្កើត ជាផម្ទជាតិ នៃប្រជាជាតិយួន ក្នុងការវិវត្តន៍ នៃមនុស្សជាតិ តែប៉ុណ្ណោះ។

ទ្រឹស្តី នៃ អវកាស ទទេ នោះ អាចនាំអោយ វៀតណាម មិនគ្រាន់តែ ប្លន់យក ទឹកដីខ្មែរបាន តាម កម្លាំងយោធា នោះឡើយ គឺ គេអាច ប្តូរ អត្តសញ្ញាណខ្មែរ តាម កម្លាំងបញ្ញា ថែមទៀត។ ប្រវត្តិសាស្ត្រ អបរភាព របស់ខ្មែរ ក្នុង ទស្សនបថ នៃពិភពលោក[5] គឺ គ្រាន់តែជារឿងបន្ទាប់បន្សំ នៅក្នុង ប្រវត្តិសាស្ត្រ នៃ ប្រជាជាតិវៀតណាម តែប៉ុណ្ណោះ ព្រោះ វៀតណាម ប្រើគ្រប់មយោបាយ ដើម្បីអោយ ប្រវត្តិសាស្ត្រ នោះ កើតឡើងបាន ហើយ ចំណេរតមក ទស្សនបថ នៃ ពិភពលោកនោះ ក្លាយជាការពិត សំរាប់យុវជនកម្ពុជា។ ម្លោះហើយ ក្នុង អនាគតដ៏ខ្លី ទឹកដីខ្មែរ សព្វថ្ងៃ ក្លាយជា ទឹកដី បុព្វបុរសយួន សំរាប់យុវជនយួន ដូច កម្ពុជាក្រោម នោះដែរ។

នៅក្នុង បរិបទ នេះ ពួក ចិត្តបណ្ឌិត (penseurs) ខ្មែរ មួយចំនួនធំ ដែលមានការដាស់តឿន ពីបញ្ហាជាតិ នាំគ្នាទៅពួនក្នុងទីជ្រក នៃ ផាសុកភាព នៃបញ្ញា[6] គឺ គំនិតអហិង្សា នៅចំពោះមុខគ្រប់បញ្ហាជាតិ។ គំនិតនេះ គឺ ជា អវកាស ទទេ ដែល យួន ជាអ្នក បង្កើត នោះឯង៕

---

[5] ប្រវត្តិសាស្ត្រ អបរភាព របស់ខ្មែរ ក្នុង ទស្សនបថ នៃពិភពលោក ; l’histoire khmère dans le futur dans le champ de vision mondiale។

[6] ផាសុកភាព នៃបញ្ញា ; confort intellectuel។